**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ.០៤២១......សហវ.[illegible]

ថ្ងៃ ពុធ ១៤រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០២៣

# សេចក្ដីណែនាំ

## ស្ដីពី

## ការអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

អនុលោមតាមច្បាប់ស្ដីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ និងព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមនីតិវិធីនៃរបបសារពើពន្ធជាធរមាន។ ក្នុងគោលបំណងដើម្បីផ្ដល់ភាពងាយស្រួលក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ និងដើម្បីគ្រប់គ្រងការប្រមូលចំណូលពន្ធប្រកបដោយប្រសិទ្ធភាព តម្លាភាព និងស័ក្ដិសិទ្ធិភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីការអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដូចខាងក្រោម៖

### ១- កាតព្វកិច្ចចុះបញ្ជី និងបច្ចុប្បន្នភាព

ក- គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល ១៥ថ្ងៃ ក្រោយចាប់ផ្ដើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬសកម្មភាពផ្សេងទៀត ឬក្រោយពីទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ។

ខ- គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវជូនដំណឹង ឬធ្វើបច្ចុប្បន្នភាព មករដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីការផ្លាស់ប្ដូរអាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដារ។

### ២- ពន្ធប៉ាតង់

ពន្ធប៉ាតង់ ត្រូវបានលើកលែងចំពោះសកម្មភាពរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងក្របខ័ណ្ឌការបំពេញបេសកកម្មផ្នែកសេវាសាធារណៈរបស់ខ្លួន សម្រាប់បម្រើប្រយោជន៍សាធារណៈ។

### ៣- អាករលើតម្លៃបន្ថែម

ក- ចំណូលដែលគ្រឹះស្ថានសាធារណៈរដ្ឋបាលទទួលបានការឧបត្ថម្ភពីថវិការដ្ឋ និងចំណូលដែលទទួលបានតាមរយៈការបំពេញបេសកកម្មផ្នែកសេវាសាធារណៈ ដែលជាកម្រៃសេវាសាធារណៈស្ថិតក្នុងឧបសម្ព័ន្ធនៃថវិការបស់ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស ឬភាគទានផ្សេងៗ មិនមែនជាកម្មវត្ថុនៃអាករលើតម្លៃបន្ថែមឡើយ។

ខ- ឥណទានអាករលើធាតុចូលដែលគ្រឹះស្ថានសាធារណៈរដ្ឋបាល បានបង់ទៅឱ្យអ្នកផ្គត់ផ្គង់ មិនត្រូវបានអនុញ្ញាតជាឥណទានអាករ និងមិនអនុញ្ញាតឱ្យស្នើសុំបង្វិលសងបានឡើយ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

**៤- ពន្ធលើប្រាក់ចំណូល**

ពន្ធលើប្រាក់ចំណូល ត្រូវបានលើកលែងចំពោះប្រាក់ចំណូលដែលទទួលបានពីការឧបត្ថម្ភថវិការដ្ឋ និងកម្រៃសេវាសាធារណៈ ព្រមទាំងចំណូលផ្សេងៗទៀត សម្រាប់បម្រើឱ្យក្របខ័ណ្ឌបំពេញបេសកកម្មផ្នែកសេវាសាធារណៈរបស់ខ្លួន និងគ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូល ត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន។

**៥- ពន្ធអាករដទៃទៀត**

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបំពេញកាតព្វកិច្ចជាភ្នាក់ងារកាត់ទុក ស្របតាមមាត្រា២៥ មាត្រា២៦ និងមាត្រា៣១ នៃច្បាប់ស្តីពីសារពើពន្ធ និងបង់ពន្ធលើប្រាក់បៀវត្ស ព្រមទាំងពន្ធអាករដទៃទៀត ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ជាធរមាន។

**៦- ការដាក់លិខិតប្រកាសសារពើពន្ធ**

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ ប្រចាំឆ្នាំ ជូនរដ្ឋបាលសារពើពន្ធ ទៅតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់ បើទោះបីជាមាន ឬគ្មានប្រាក់ពន្ធត្រូវបង់ក៏ដោយ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- គ្រប់ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ឯកសារ-កាលប្បវត្តិ